00777475

**លេខ / No: D28**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស.**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Laurent KASPER-ANSERMET**

កាលបរិច្ឆេទ ៖ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១

ភាសា ៖ អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

---

# ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ

---

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី ជា លាង

លោក Andrew CAYLEY

០០៣/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស. លេខ/No: D28

យើង **Laurent Kasper-Ansermet** សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

បានឃើញកិច្ចព្រមព្រៀង ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា និង ច្បាប់អន្តរជាតិ ដែលប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ (កិច្ចព្រមព្រៀងស្តីអំពី អ.វ.ត.ក)

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (“ច្បាប់ស្តីពី អ.វ.ត.ក”)

បានឃើញវិធាន៥៥ វិធាន៥៦ វិធាន៦៧ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក (“វិធានផ្ទៃក្នុង”)

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចូលធរមានថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៧ ដែលត្រូវអនុវត្តក្នុងករណីដែលវិធានផ្ទៃក្នុង អ.វ.ត.ក មិនមានបញ្ញត្តិច្បាស់លាស់

បានឃើញការស៊ើបសួរលើបទចោទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ការធ្វើទារុណកម្ម និងការធ្វើមនុស្សឃាត បទល្មើសដែលមានចែងនៅក្នុងមាត្រា៣,៤,៥,៦,២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥០០,៥០១,៥០៣,៥០៥,៥០៦,៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ប្រឆាំងនឹងជនសង្ស័យពីររូប

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ពាក់ព័ន្ធនឹងសំណុំរឿងលេខ ០០៣[1] ស្នើសុំឲ្យមានការចាប់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្នជនសង្ស័យ

---

[1] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ D1 ។

ដោយអនុវត្តវិធាន៤២ និង ៦៣ ហើយដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ត្រូវបានដាក់ចូលក្នុងសំណុំរឿងនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩[2]

## ការរំលឹកឡើងវិញអំពីនីតិវិធី

បានឃើញការជូនដំណឹងអំពីការបិទការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១១[3]

បានឃើញសំណើបំពេញកិច្ចស៊ើបសួរទាំងបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ សុំឱ្យទទួលយកឯកសារបន្ថែម[4] និងបំពេញកិច្ចស៊ើបសួរដើម្បីកំណត់ការទទួលខុសត្រូវរបស់ជនសង្ស័យ[5]

បានឃើញសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១[6] បដិសេធមិនទទួលយកសំណើសុំខាងលើ ដោយហេតុថាសំណើសុំទាំងនោះត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិតែឯកឯង ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិត្រូវបំពេញកិច្ចរួមគ្នាជាមួយនឹងសហសេវិកជាតិរបស់ខ្លួន ឬត្រូវមានសេចក្តីសម្រេចផ្ទេរអំណាច (វិធាន ១៣.៣) ឬកំណត់ហេតុខ្វែងយោបល់ (វិធាន ៧១.១)

---

[2] ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ D1/1 ។

[3] ការជូនដំណឹងអំពីការបិទការស៊ើបសួរ ថ្ងៃ ២៩ ខែ មេសា ឆ្នាំ ២០១១ D13 ។

[4] សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿងលេខ ០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ D17 ។

[5] សំណើលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹង[ជនសង្ស័យ] ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ D18 ។ សំណើបំពេញកិច្ចស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ D19 ។

[6] ដីកាសម្រេចស្តីអំពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ D20/3 ។

បានឃើញការជូនដំណឹងថ្មីនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ អំពីសំណើសុំបំពេញកិច្ចស៊ើបសួរខាងលើ[7] បន្ទាប់ពីការដាក់ចូលក្នុងសំណុំឯកសារដោយឡែកនៃកំណត់ហេតុនៃការខ្វែងយោបល់ ដោយទាមទារឲ្យមានការទទួលយកសំណើសុំទាំងនោះ ទោះបីជាថិរវេលាកំណត់រយៈពេល ១៥ ថ្ងៃ បានផុតរលត់ហើយក៏ដោយ (វិធាន៦៦.១ និង៣៩.៤)

បានឃើញបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងសេចក្ដីសម្រេចថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១[8] (វិធាន ៧៤.២ និង ៧៥.១)

បានឃើញសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ បដិសេធមិនទទួលយកសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី ដែលបានធ្វើនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១[9] ដោយហេតុថា៖

ក) អង្គបុរេជំនុំជម្រះ ដែលត្រូវបានប្ដឹងរួចហើយ គឺជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចអំពីសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបីដំបូងនោះ ។

ខ) សហចៅក្រមស៊ើបអង្កេតមិនអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនបានទេ (វិធាន ៣៩.៤) ។

គ) ការពន្យារថិរវេលា ១៥ ថ្ងៃ (វិធាន ៦៦.១) ដែលបានកំណត់ដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ គឺជាការរំលោភលើគោលការណ៍ ដែលតម្រូវឲ្យនីតិវិធីមានដំណើរការឆាប់រហ័ស (វិធាន ២១.៤) ។

---

[7] សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿងលេខ ០០៣ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្ដីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ D22 ។ ការដាក់ឡើងវិញ សំណើលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធ នឹង[ជនសង្ស័យ] ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ចុះថ្ងៃទី ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ ។ សំណើបំពេញកិច្ចស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹង [ជនសង្ស័យ] និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ D24 ។

[8] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹង "សេចក្ដីសម្រេចស្ដីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ D20/4/1 ។

[9] ដីកាសម្រេចស្ដីអំពីការដាក់សារជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១១ D26/1/1 ។

ឃ) សហព្រះរាជអាជ្ញាអន្តរជាតិ ដែលអាចនឹងស្នើសុំបំពេញកិច្ចស៊ើបសួរចាប់តាំងពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ ប៉ុន្តែបានរង់ចាំរហូតដល់មានការជូនដំណឹងអំពីការបិទការស៊ើបសួរ ទើបធ្វើសំណើសុំ ។

ង) សហព្រះរាជអាជ្ញាអន្តរជាតិមិនបានពិចារណាឲ្យបានហ្មត់ចត់អំពីបទប្បញ្ញត្តិនៃមាត្រា២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងអំពីយុត្តាធិការលើបុគ្គល ដែលជាបញ្ហាមួយដែលត្រូវពិនិត្យ ជាអាទិភាពជាងកិច្ចស៊ើបសួរដទៃទៀត ព្រោះការបំពេញកិច្ចស៊ើបសួរដទៃទៀតអាចនាំឲ្យមានការចំណាយធនធានរបស់តុលាការដោយឥតប្រយោជន៍ និងដោយមិនទទួលខុសត្រូវ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ ប្រឆាំងនឹងសេចក្តីសម្រេចខាងលើ[10] ដែលលើកឡើងថា សិទ្ធិរបស់ខ្លួន និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីសក្តានុភូត ត្រូវបានប៉ះពាល់ដោយហេតុថា ការស៊ើបសួរមិនមានលក្ខណៈពេញលេញយ៉ាងជាក់ច្បាស់ ម្យ៉ាងទៀតថា សហចៅក្រមស៊ើបអង្កេតមិនអាចបង្កើតនូវការសន្និដ្ឋានមួយ ដែលគាត់មិនបានបំពេញតាមទំរង់ និងធ្វើការជូនដំណឹង ដោយមិនបានធ្វើការកំណត់ជាមុនអំពីឋានៈនៃជនសង្ស័យ និងប្រភេទពិតប្រាកដនៃបទល្មើសដែលចោទប្រកាន់ តាមរយៈការស៊ើបអង្កេតដែលមានលក្ខណៈគ្រប់គ្រាន់បានឡើយ ។

បានឃើញការពិចារណារបស់អង្គបុរេជំនុំជម្រះថ្ងៃទី ០២[11] និងថ្ងៃទី ១៥[12] ខែ វិច្ឆិកា ឆ្នាំ ២០១១ ដែលធ្វើឲ្យសេចក្តីសម្រេចថ្ងៃ ០៧ ខែ មិថុនា និងថ្ងៃ ២៧ ខែ កក្កដា ឆ្នាំ ២០១១ ចូលជាធរមាន ដោយសារមិនមានសម្លេងភាគច្រើនលើសលប់របស់ចៅក្រោម (វិធាន ៧៧.១៣) ។

**I.**

[10] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង "ដីកាសម្រេចស្តីអំពីការដាក់សារជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣" ថ្ងៃ២៧ ខែសីហា ឆ្នាំ២០១១ D26/1/11 ។

[11] ការពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងសេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១ D20/4/4 ។

[12] ការពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចស្តីអំពីការដាក់សារជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ D26/1/3 ។

១. ដោយហេតុថា ចៅក្រមដែលចុះហត្ថលេខាខាងក្រោម ក្នុងឋានៈជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានចាប់ផ្តើមបំពេញមុខងាររបស់ចៅក្រមលោ ស៊ីហ្វ្រីត ប្លុង Siegfried Blunk ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។

## II.

២. ដោយហេតុថា ការស៊ើបសួរនឹងបញ្ចប់ជាស្ថាពរ តាមរយៈដីកា "ដំណោះស្រាយ" (វិធាន ៦៧.១) ឬ "ដំណោះស្រាយ" (មាត្រា ២៤៧.១ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា) ដែលអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ។

ដោយហេតុថា មកដល់ត្រឹមពេលនេះ សហចៅក្រមស៊ើបអង្កេតនៅមានសមត្ថកិច្ចនៅលើសំណុំរឿងនៅឡើយ[13] ។

ដោយហេតុថា សហចៅក្រមស៊ើបអង្កេតមានសិទ្ធិក្នុងពិនិត្យឡើងវិញនូវរាល់សេចក្តីសម្រេចទាំងអស់ ដែលបានធ្វើកាលពីពេលមុន ទោះបីជាក្រោយពេលនៃការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ក៏ដោយ[14] ។

៣. ដោយហេតុថា បន្ទាប់ពីបានឃើញកិច្ចនីតិវិធីទាំងឡាយ ដែលរៀបរាប់ខាងលើ ចៅក្រមដែលចុះហត្ថលេខាខាងក្រោម មានបំណងពិនិត្យឡើងវិញនូវភាពអាចទទួលយកបាននៃសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី ដែលធ្វើឡើងយឺតយ៉ាវដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ។

## III.

៤. ដោយហេតុថា វិធានផ្ទៃក្នុង និងច្បាប់កម្ពុជាមិនមានចែងបទប្បញ្ញត្តិច្បាស់លាស់ ចាំបាច់ត្រូវយោងទៅដល់ច្បាប់អន្តរជាតិ (មាត្រា ១២.១ នៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក មាត្រា២៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក)

---

[13] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងហេតុរបស់ ខៀវ សំផន ដែលមានគោលដៅផ្អាកភ្លាមៗនិងជាស្ថាពរនូវនីតិវិធីដោយមូលហេតុមានការរំលោភនីតិវិធី, អង្គបុរេជំនុំជម្រះ ថ្ងៃទី១២ ខែមករា ឆ្នាំ២០១១, ឯកសារលេខ២ កថាខណ្ឌ ៦ ។

[14] នៅក្នុងយុត្តិសាស្ត្រតុលាការបារាំង តុលាការកំពូល សភាព្រហ្មទណ្ឌ ថ្ងៃ០៩ ខែមករា ឆ្នាំ១៩៩៥ បណ្តឹងសារទុក្ខ លេខ 94-84975 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ៦ (D 1995 Somm 322 obs Pradel JCP 1996 I 3906 chron J-H Robert) ។ តុលាការព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌ ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៩៨ បណ្តឹងសារទុក្ខ លេខ98-81678 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ២២០ ។

ដោយហេតុថា ច្បាប់អន្តរជាតិចែងថា ការពិនិត្យឡើងវិញលើសេចក្តីសម្រេច ដែលធ្វើរួចហើយ អាចធ្វើទៅបានចំពោះទឡ្ហីករណ៍ស្របច្បាប់ មិនត្រឹមតែនៅក្នុងករណីនៃការផ្លាស់ប្តូរកាលៈទេសៈ (អង្គហេតុថ្មី ទឡ្ហីករណ៍ថ្មី) ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវអនុវត្តផងដែរចំពោះករណីដែលសេចក្តីសម្រេចត្រូវបានធ្វើឡើងដោយភ័ន្តច្រឡំ ឬបង្ករឲ្យមានភាពអយុត្តិធម៌[15] ។

ដោយហេតុថា វាគឺជា "អំណាចផ្ទាល់" របស់ចៅក្រម[16] ដែលមានអំណាចធ្វើការពិនិត្យដោយឆន្ទានុសិទ្ធិ ដែលអំណាចនេះត្រូវបានទទួលស្គាល់ដោយច្បាប់ និងយុត្តិសាស្ត្រ[17] ។

ដោយហេតុថា អង្គបុរេជំនុំជម្រះធ្លាប់បានធ្វើការពិនិត្យឡើងវិញនូវសេចក្តីសម្រេចមុនៗរបស់ខ្លួន[18]។

---

[15] រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Milosevic IT-02-54-T សេចក្តីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាដើម្បីសុំឲ្យមានការពិចារណាឡើងវិញអំពីសក្ខីកម្មរបស់សាក្សីរបស់មេធាវីការពារក្តី Mitar Balevic, Vladislav Jovanovic, Vukasin Andric និង Dobre Aleksovski និងសេចក្តីសម្រេចតាមការផ្តួចផ្តើមផ្ទាល់ឲ្យមានការពិចារណាឡើងវិញអំពីការទទួលយកភស្តុតាង ៨៣៧ និង៨៣៨ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីមេធាវីការពារក្តី Barry Lituch អង្គជំនុំជម្រះសាលាដំបូង ថ្ងៃ ១៧ ខែ ឧសភា ឆ្នាំ ២០០៥ ។ រដ្ឋអាជ្ញា ទល់នឹង Galic IT-98-29-54-AR73 សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំឲ្យទទួលយកបណ្តឹងឧទ្ធរណ៍, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃ១៤ ខែធ្នូ ឆ្នាំ២០០១ កថាខណ្ឌ១៣ ។ រដ្ឋអាជ្ញា ទល់នឹង Mucic និងអ្នកផ្សេងទៀត IT-96-21-Abis សាលក្រមលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការសម្រេចទោស អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៣ កថាខណ្ឌ៤៩ ។ រដ្ឋអាជ្ញា ទល់នឹង Milutinovic និងអ្នកផ្សេងទៀត IT-05-87-T សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំឲ្យមានការពិចារណាឡើងវិញអំពីសេចក្តីសម្រេចលើសំណើរបស់អយ្យការ សុំឲ្យបន្ថែមវិធានការការពារពាក់ព័ន្ធនឹងសវនការ សម្រាប់សាក្សី K56 អង្គជំនុំជម្រះសាលាដំបូង ថ្ងៃ ៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ២ ។

[16] រដ្ឋអាជ្ញា ទល់នឹង Galic IT-98-29-54-A សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តីសុំឲ្យមានការពិចារណាឡើងវិញ, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃ ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ២ ។

[17] Milosevic ទល់នឹង សហព្រះរាជអាជ្ញា IT-02-29-54-AR73.7 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការតែងតាំងក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃ០១ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ ៩-១០ យោងនៅក្នុង សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃ១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ D164/4/13 កថាខណ្ឌ ២៦ ។

[18] សេចក្តីសម្រេចលើសំណើសុំឲ្យមានការពិចារណាឡើងវិញអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការឆ្លើយតបចំពោះអង្គបុរេជំនុំជម្រះដោយមានវត្តមានបុគ្គល សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ថ្ងៃ ២៨ ខែ សីហា ឆ្នាំ២០០៨ C22/I/68 កថាខណ្ឌ ២៥ និងសេចក្តីសម្រេចទាក់ទងនឹងការពិនិត្យឡើងវិញអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ថ្ងៃ ០១ ខែ កក្កដា ឆ្នាំ ២០១១ D364/1/6 កថាខណ្ឌ ៩ ។

៥. ដោយហេតុថា នៅក្នុងច្បាប់អន្តរជាតិ មានបញ្ញត្តិចែងថា ការជូនដំណឹងដែលមានលក្ខណៈយឺតយ៉ាវ អាចត្រូវបានទទួលយក៖

ក) "ទម្លាក់ករណ៍ស្របច្បាប់" (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយោហ្គោស្លាវី, វិធាន នីតិវិធី និងភ័ស្តុតាង (វិសោធនកម្មលើកទី ៤៥) មាត្រា ១២៧ ។ តុលាការពិសេសសម្រាប់សេរ៉ាឡេអូន, វិធាននីតិវិធី និងភ័ស្តុតាង វិធាន១១៦) ។

ខ) ឬដើម្បី "ផលប្រយោជន៍យុត្តិធម៌" (តុលាការព្រហ្មទណ្ឌអន្តរជាតិ, បទបញ្ញា, វិធាន២៩)[19]។

ដោយហេតុថា នៅក្នុងបរិការណ៍នេះ តម្រូវឲ្យមានការថ្លឹងថ្លែងអំពីផលប្រយោជន៍ពាក់ព័ន្ធ រវាងម្ខាងសារៈសំខាន់នៃសិទ្ធិ និងកាតព្វកិច្ចនៃអយ្យការ និងម្ខាងទៀតព្យសនកម្មដែលអាចកើតមានចំពោះភាគីផ្សេងទៀត[20] ។

ចំពោះបញ្ហានៃការជូនដំណឹងយឺតយ៉ាវ វិធាន ៣៩.៤ ចែងយ៉ាងច្បាស់ថា៖

*"តាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអាច៖ ខ) ទទួលស្គាល់ថាមានសុពលភាព ចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេលកំណត់ ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ ត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល"* ។

ដោយហេតុថា អង្គបុរេជំនុំជម្រះផ្ទាល់ ត្រូវបាននាំឲ្យទទួលយកសំណើសុំដែលយឺតយ៉ាវ ដើម្បីផលប្រយោជន៍នៃយុត្តិធម៌[21] ។

---

[19] សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Brima SCSL-04-16-T សេចក្តីសម្រេចលើសំណើបន្ទាន់របស់ក្រុមមេធាវីការពារក្តីក្រោមវិធាន ៥៤ ទាក់ទងនឹងការដាក់សំណើសុំឲ្យមានការដោះលែង អង្គជំនុំជម្រះសាលាដំបូង II ថ្ងៃ ១៩ ខែ មករា ឆ្នាំ ២០០៦។

[20] រដ្ឋអាជ្ញា ទល់នឹង Lukic IT-98-29-32/1-AR65.1 សេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពីសំណើរបស់ Sreboje Lukie សុំឲ្យមានការដោះលែងនៅក្រៅឃុំ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃ ១៦ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ១២ ។ រដ្ឋអាជ្ញា ទល់នឹង Boskoski និង Tarculovski IT-04-82-/AR65.3 សេចក្តីសម្រេចអំពីបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុរបស់ Ljube Boskoski ទាក់ទងនឹងសំណើលើកទីពីរ សុំឲ្យមានការដោះលែងឲ្យនៅក្រៅឃុំ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃ ២៨ ខែ សីហា ឆ្នាំ ២០០៦ កថាខណ្ឌ៩ ។ រដ្ឋអាជ្ញា ទល់នឹង Muvunyi ICTR-200-55A-A សេចក្តីសម្រេចលើ "សំណើរបស់ជនត្រូវចោទ Tharcisse Muvunyi សុំឲ្យទទួលយកការកែប្រែមូលដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍ និងសំណើសុំពន្យារចិរវេលាក្នុងការដាក់សារណាសង្ខេបបណ្តឹងឧទ្ធរណ៍" និង "សំណើរបស់រដ្ឋអាជ្ញាប្រឆាំងទៅនឹង "សំណើរបស់ជនត្រូវចោទ Tharcisse Muvunyi សុំឲ្យទទួលយកការកែប្រែមូលដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ថ្ងៃ ១៩ ខែ មីនា ឆ្នាំ ២០០៧ កថាខណ្ឌ៧ លេខយោងចុងទំព័រ ២២ ។

[21] សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជិតចិត្តជាបន្ទាប់របស់សហមេធាវី ចំពោះលោកចៅក្រម ន៍យ ថុល ព្យួរបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណី នួន ជា សំណុំរឿង០០២/១៩-០៩-២០០៧-អ.វ.ត.ក/

**IV.**

៦. ដោយហេតុថា ពាក់ព័ន្ធនឹងទឡ្ហីករណ៍ដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេតដើម្បីបដិសេធ មិនទទួលយកសំណើសុំបំពេញកិច្ចស៊ើបសួរ ការណ៍ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ត្រូវបានប្ដឹង គឺមិនបានច្រានចោលនូវសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើសេចក្ដីសម្រេចទាក់ទងនឹងសំណើសុំបំពេញកិច្ចស៊ើបសួរដែលយឺតយ៉ាវ ប៉ុន្តែត្រូវបានធ្វើនិយ័តភាពនោះទេ (វិធាន ៧៧.១១) ។

ដោយហេតុថា ការជូនដំណឹងថ្មីអំពីសំណើសុំទាំងនោះ ដែលមានភ្ជាប់មកជាមួយនូវកំណត់ហេតុនៃការខ្វែងយោបល់ បានបញ្ជាក់អំពីសុឆន្ទៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។

ដោយហេតុថា ទោះក្នុងកាលៈទេសៈណាក៏ដោយ សហចៅក្រមស៊ើបអង្កេតគួរត្រូវរង់ចាំសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដើម្បីធ្វើការសម្រេចជាស្ថាពរ ។

ដោយហេតុថា វាមិនមែនជាពេលវេលាដែលត្រឹមត្រូវ ក្នុងការបន្ទោសទៅដល់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរយឺតយ៉ាវ ក្នុងកាលៈទេសៈដែលថា៖

ក) របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់អ្នកស៊ើបអង្កេតពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ និងបញ្ចប់ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១១[22] ត្រូវបានដាក់ចូលក្នុងសំណុំរឿងនៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ ។

ខ) ភ័ស្តុតាងផ្សេងទៀតត្រូវបានដាក់ចូលក្នុងសំណុំរឿង នៅក្នុងខែមុនការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ (ឯកសារជាងមួយពាន់ត្រូវបានផ្ទេរពីសំណុំរឿង០០២ នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១១ ហើយនិងជាង ១៣០ ទៀតដែលត្រូវបានផ្ទេរនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១, កំណត់ហេតុស្ដាប់ចម្លើយជាច្រើនរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានផ្ទេរក្នុងចន្លោះថ្ងៃ ២៦ និង ២៨ ខែ មេសា ឆ្នាំ

---

ក.ស.ច.ស ថ្ងៃ ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ៨ ។ សេចក្ដីទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យមានការពន្យារចិរវេលាកំណត់ និងបន្ថែមការកំណត់ចំនួនទំព័រ ដែលអនុញ្ញាតដើម្បីអាចដាក់ចម្លើយតបតែមួយទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធិ ខៀវ សំផន និង អៀង សារី និងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ប្រឆាំងនឹងដីកាសម្រេចលើភាពអាចអនុវត្តបាននៃទ្រឹស្ដីសហឧក្រិដ្ឋកម្មរួមនៅចំពោះមុខ អ.វ.ត.ក សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ថ្ងៃទី ៩ ខែកុ ម្ភៈ ឆ្នាំ ២០១០ កថាខណ្ឌ ០៧ ។

[22] របាយការណ៍អនុវត្តបញ្ចប់ដីកាចាត់ឲ្យស៊ើបសួរ ថ្ងៃ ១០ ខែ កុម្ភៈ ឆ្នាំ ២០១១ D2/1 ។

២០១១[23], ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងពាក្យប្ដឹងជនរងគ្រោះជាច្រើនត្រូវបានផ្ទេរ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១) ។

ដោយហេតុថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានមានពេលវេលាគ្រប់គ្រាន់ដើម្បីចូលមើលសំណុំរឿងដែលបានធ្វើបច្ចុប្បន្នកម្ម និងមូល (វិធាន ៥៥.៦) ដែលនេះធ្វើឲ្យការបំពេញភារកិច្ចរបស់គាត់ក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរ ដែលគាត់យល់ថាសំខាន់ចាំបាច់ មានការលំបាក (វិធាន ៥៥.១០) ។

ដោយហេតុថា គោលការណ៍ដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលតាមរយៈគោលការណ៍នោះនីតិវិធីត្រូវដំណើរការក្នុងថិរវេលាមួយឆាប់រហ័ស មិនអាចនឹងប៉ះពាល់ការគ្រប់គ្រងរដ្ឋបាលល្អរបស់តុលាការ ដែលតម្រូវឲ្យមានការស៊ើបសួរពេញលេញ ក្នុងប្រយោជន៍របស់គ្រប់ភាគីទាំងអស់នោះទេ (វិធាន ៥៥.១) ។

ដោយហេតុថា ជាក់ស្ដែង មានការលេចឡើងនៅក្នុងដំណើរការនីតិវិធី នូវរបាយការណ៍មួយធ្វើឡើងនៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០ ដោយមានការលើកឡើងថា "ការស៊ើបសួរនៅមិនទាន់ត្រូវបានបញ្ចប់"[24]។

៧. ដោយហេតុថា ម្យ៉ាងទៀត គិតមកដល់ពេលនេះ ជនសង្ស័យ ដែលមិនធ្លាប់ត្រូវបានស្ដាប់ចម្លើយនៅឡើយនោះ មានផលប្រយោជន៍ជាក់ច្បាស់ក្នុងការនិយាយអំពីបទចោទប្រកាន់ ដែលមានប្រឆាំងនឹងពួកគាត់។

ដោយហេតុថា ជនរងគ្រោះមិនអាចត្រូវបានដកហូតសិទ្ធិក្នុងការទទួលបានការស្ដាប់ចម្លើយ សិទ្ធិទទួលបានយុត្តិធម៌ សិទ្ធិទទួលបានការពិត និងសិទ្ធិទទួលបានសំណងខូចខាត ដោយមិនមានទឡ្ហីករណ៍ស្របច្បាប់ឡើយ[25] ។

---

[23] កំណត់ហេតុស្ដាប់ចម្លើយសាក្សី ថ្ងៃ ២៤ ខែ មីនា ឆ្នាំ ២០១១ D6 ដាក់ចូលក្នុងសំណុំរឿងថ្ងៃ ២៦ ខែ មេសា ឆ្នាំ ២០១១ ។ កំណត់ហេតុស្ដាប់ចម្លើយសាក្សី ថ្ងៃ ២៥ ខែ មីនា ឆ្នាំ ២០១១ D8 ដាក់ចូលក្នុងសំណុំរឿង ថ្ងៃ ២៦ ខែ មេសា ឆ្នាំ ២០១១ ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ថ្ងៃ ២៧ ខែ មេសា ឆ្នាំ ២០១១ D12 ដាក់ចូលក្នុងសំណុំរឿងថ្ងៃ ២៨ ខែ មេសា ឆ្នាំ ២០១១។

[24] របាយការណ៍អំពីស្ថានភាពភូមិសាស្ត្រ ចុះថ្ងៃ ទី៣០ ខែ ធ្នូ ឆ្នាំ ២០១០ D2/23 ទំព័រ៣ ។

[25] ដើម្បីសិទ្ធិទទួលបានការពិត៖ អង្គការសហប្រជាជាតិ គណៈកម្មាធិការសិទ្ធិមនុស្ស *របាយការណ៍របស់អ្នកជំនាញការឯករាជ្យទទួលបន្ទុកធ្វើបច្ចុប្បន្នកម្មសំណុំនៃគោលការណ៍ដើម្បីប្រយុទ្ធប្រឆាំងនិទណ្ឌភាព* Diane Orentlicher - អត្ថបទ

០០៣/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស. លេខ/No: D28

ដោយហេតុថា មិនមានការពិនិត្យលើសំណុំពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងមូល ដែលខ្លះក្នុងចំណោមនោះ ទាមទារឲ្យមានកិច្ចស៊ើបសួរបន្ថែម (ឧទាហរណ៍ ពាក្យសុំ 11-VSS-00064)។

ដោយហេតុថា ការបដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងបួន មានមូលដ្ឋានលើលក្ខណៈវិនិច្ឆ័យដែលចង្អៀតជាងលក្ខណៈវិនិច្ឆ័យរបស់អង្គបុរេជំនុំជម្រះ និងយុត្តិសាស្ត្រអន្តរជាតិ ដែលការណ៍នេះ ចាំបាច់ត្រូវធ្វើការពិនិត្យឡើងវិញ ។

**V.**

៨. ដោយហេតុថា ការស៊ើបសួរដែលបានធ្វើកន្លងមក មកដល់ពេលនេះ ហាក់ដូចជាមានលក្ខណៈខ្វះចន្លោះ និងប៉ះពាល់ដល់ផលប្រយោជន៍របស់គ្រប់ភាគីទាំងអស់ ។

ដោយហេតុថា ការស៊ើបសួរបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិជនសង្ស័យ ជនរងគ្រោះ និងអយ្យការ។

ដោយហេតុថា ភាពខ្វះចន្លោះទាំងអស់នេះមិនបានរួចផុតពីក្រសែភ្នែករបស់តំណាងសង្គមស៊ីវិល ដែលបានប្រតិកម្មតបយ៉ាងសកម្មទៅនឹងការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង០០៣។

ដោយហេតុថា ពេលនេះផលប្រយោជន៍សាធារណៈទទួលរងការប៉ះពាល់ ។

៩. ដោយហេតុថា នៅក្នុងកាលៈទេសៈបែបនេះ សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីទទួលយកសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី ដែលធ្វើនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១១ (វិធាន ៥៥.១ និង ៥៥.៥) ទោះបីជាសំណើសុំទាំងនោះត្រូវបានធ្វើឡើងដោយមានភាពយឺតយ៉ាវ និងសម្រេចលើកិច្ចស៊ើបសួរដែលនឹងត្រូវបំពេញ ។

ដោយហេតុថា យោងទៅលើផលវិបាកនៃការបដិសេធមិនទទួលយករបស់ខ្លួនលើដំណើរការបន្តនៃនីតិវិធី សហចៅក្រមស៊ើបអង្កេតមិនអាចយកភាពមិនប្រក្រតីដែលមានលក្ខណៈនីតិវិធីសុទ្ធសាធមកធ្វើជាមូលដ្ឋានបានឡើយ ។

---

បន្ថែម ថ្ងៃ ៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ E/CN.4/2005/102/Add.1 គោលការណ៍ ២ ដល់ ១៨ ។ ដើម្បីសិទ្ធិទទួលបានយុត្តិធម៌៖ គោលការណ៍ ១៩ ។ ដើម្បីសិទ្ធិទទួលបានសំណងខូចខាត៖ គោលការណ៍ ៣១ ដល់ ៣៨ ។

ដោយហេតុថា ការបដិសេធមិនទទួលយកសំណើសុំបំពេញកិច្ចស៊ើបសួរថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៩ អាចត្រូវបានប្រដូចទៅនឹង "ការបដិសេធមិនជូនដំណឹង" ដែលផ្ទុយទៅនឹងកាតព្វកិច្ចស៊ើបសួរលើមូលដ្ឋាននៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨[26] ។

១០. ចុងក្រោយ ដោយហេតុថា នៅក្នុងដំណាក់កាលនេះ សហចៅក្រមស៊ើបអង្កេតមិនអាចលើកឡើងអំពីកាតព្វកិច្ចជាអាទិភាពនៃការពិនិត្យលើយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ។

ដោយហេតុថា សញ្ញាណនៃ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែលកំណត់អំពីយុត្តាធិការរបស់តុលាការ (មាត្រា២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក) បច្ចុប្បន្នកំពុងជាប់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដែលត្រូវចេញការពិចារណានៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ នៅក្នុងក្របខណ្ឌនៃបណ្តឹងរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០[27] ។

ដោយហេតុថា សហចៅក្រមស៊ើបអង្កេតត្រូវពិចារណាអំពីនិយមន័យដែលនឹងត្រូវកំណត់យកដើម្បីធ្វើសេចក្តីសម្រេច ។

ដោយហេតុថា នៅក្នុងបរិការណ៍នេះ ការស៊ើបសួរមានលក្ខណៈចាំបាច់ ដើម្បីវិភាគជាពិសេសលើស្ថានភាពឋានានុក្រមជនសង្ស័យ កម្រិតនៃអំណាចដែលពួកគេមានក្នុងអំឡុងពេលនៃអង្គហេតុ ដែលពួកគេត្រូវបានចោទប្រកាន់ ។

## VI.

១១. ដោយយោងលើទឡ្ហីករណ៍ដែលបង្ហាញខាងលើ សេចក្តីសម្រេចថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ ដែល បានបដិសេធមិនទទួលយកសំណើបំពេញកិច្ចស៊ើបសួរថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ដូចជាមានការភ័ន្តច្រឡំក្នុងការពិចារណា និងត្រូវបានធ្វើឡើងដោយមិនមានទឡ្ហីករណ៍ស្របច្បាប់ ។

---

[26] នៅក្នុងនីតិវិធីព្រហ្មទណ្ឌបារាំង សូមមើល Christian Guery ការស៊ើបអង្កេតបឋម ព្រឹត្តិបត្រព្រហ្មទណ្ឌ Dalloz កថាខណ្ឌ ១៤៧ ។ Pierre Chambon និង Christian Guery នីតិ និងការអនុវត្តនៃការស៊ើបអង្កេតបឋម Dalloz Action ២០០៧-២០០៨ កថាខណ្ឌ ២១.១៤ ។ សភាព្រហ្មទណ្ឌ តុលាការកំពូល ថ្ងៃ១៨ ខែកក្កដា ឆ្នាំ១៩៩១ ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ ៣០០ ។ សភាព្រហ្មទណ្ឌ តុលាការកំពូល ថ្ងៃ ២៦ កុម្ភៈ ១៩៩៧ ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ៧៧ ។ សភាព្រហ្មទណ្ឌ តុលាការកំពូល ថ្ងៃ៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ ៤២ ។

[27] ការប្រកាសប្តឹងឧទ្ធរណ៍របស់សហមេធាវី កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រឆាំងនឹងសាលក្រម ថ្ងៃ ២៦ កក្កដា ២០១០ ដោយអង្គជំនុំជម្រះសាលាដំបូង សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ E188/8 កថាខណ្ឌ ៧ ។

០០៣/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស. លេខ/No: D28

ដោយហេតុថា សេចក្តីសម្រេចនោះមិនឆ្លើយតបទៅនឹងផលប្រយោជន៍នៃយុត្តិធម៌ បង្កឲ្យមានព្យសនកម្មឥតប្រកែកបានចំពោះគ្រប់ភាគីទាំងអស់នៃនីតិវិធី ។

ដោយហេតុថា ដើម្បីផលប្រយោជន៍សាធារណៈ ត្រូវចាប់ផ្តើមបើកដោយឥតរង់ចាំនូវការស៊ើបសួរបឋមឡើងវិញ ដើម្បីបំពេញកិច្ចស៊ើបសួរឲ្យបានពេញលេញ ឲ្យសមស្របទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើស ដែលចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

ដោយហេតុថា ការបើកការស៊ើបសួរឡើងវិញនេះអនុលោមជាពិសេសតាមកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក និងវិធាន ២១.១ (ក) ដែលចែងថា៖ *“បទបញ្ញាផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព... ។ ក្នុងបរិបទនេះ៖ ក) ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ។ នីតិវិធីត្រូវធានាឲ្យបាននូវភាពដាច់ដោយឡែកពីគ្នា រវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស”* ។

## អាស្រ័យហេតុនេះ សម្រេច

**ទទួលយក**សំណើសុំបំពេញកិច្ចស៊ើបសួរ ដែលដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ បន្ទាប់ពីការពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ ។

**ប្រកាសថា** ត្រូវបើកការស៊ើបសួរបឋមនៅក្នុងសំណុំរឿង០០៣ ដោយឈរលើមូលដ្ឋាននៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១**

**សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ**

**Co-juge d’instruction de réserve international**
**International Reserve Co- Investigating Judge**

**Laurent Kasper-Ansermet**